ច្បាប់ចម្លង

# ព្រះរាជក្រឹត្យ

នស/រកត/០៩២១/៣២៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៦ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៧ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យដំណើរការសាលាដំបូងខេត្តកែប ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ នេះតទៅ។

នៅអមសាលាដំបូងខេត្តកែប មានអយ្យការមួយ ស្របតាមបទប្បញ្ញត្តិដូចមានចែងនៅក្នុងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងច្បាប់ជាធរមានពាក់ព័ន្ធដទៃផ្សេងទៀត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ២.-**

សាលាដំបូងខេត្តកែប មានទីតាំងស្ថិតនៅក្នុងខេត្តកែប និងមានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីស្ថិតក្នុងសមត្ថកិច្ចដែនដីដែលគ្របដណ្ដប់លើខេត្តកែប ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា ៣.-**

សាលាដំបូងខេត្តកែប មានសមត្ថកិច្ចជំនុំជម្រះរឿងក្ដីដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ នេះតទៅ។

ចំពោះសំណុំរឿងក្ដីទាំងឡាយណាដែលស្ថិតក្នុងសមត្ថកិច្ចរបស់សាលាដំបូងខេត្តកែប ហើយដែលសាលាដំបូងខេត្តកំពតបានទទួលចាត់ការជាសមត្ថកិច្ច នៅមុនថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១នោះ សាលាដំបូងខេត្តកំពតត្រូវបន្តចាត់ការជាសមត្ថកិច្ចដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

វិធានដែលមានចែងក្នុងកថាខណ្ឌទី១ និងទី២ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអយ្យការអមសាលាដំបូងខេត្តកំពត។

**មាត្រា ៤.-**

ក្នុងករណីដែលសាលាដំបូងខេត្តកែបមិនអាចដំណើរការបាន សមត្ថកិច្ចជំនុំជម្រះរឿងក្ដីដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សាលាដំបូងខេត្តកែបនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូងខេត្តកំពត។ ក្នុងករណីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ត្រូវចេញប្រកាស ដើម្បីកំណត់អំពីការមិនអាចដំណើរការបាននៃសាលាដំបូងខេត្តកែប និងកំណត់ជាថ្មីអំពីកាលបរិច្ឆេទនៃការចាប់ផ្ដើមដំណើរការនៃសាលាដំបូងនេះ។

ប្រសិនបើសាលាដំបូងខេត្តកែបមានចៅក្រមមិនគ្រប់គ្រាន់ ឬខ្វះខាតចៅក្រមដោយមូលហេតុវិសមិតភាពជាអាទិ៍ ប្រធានសាលាដំបូងខេត្តកែបត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីចាត់តាំងចៅក្រមពីសាលាដំបូងផ្សេងទៀតមកបំពេញការងារតាមការចាំបាច់។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៦.-**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ។

នស/រកត.០៤២១.៣៧៤៩

បានឡប្រទាប់ព្រះរាជលញ្ឆករហើយ

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២១*

**នរោត្តម សីហមុនី**